**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ:២៩៩ប្រ
ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៤
**សាលដីកា**
លេខ:១៦៨
ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៥

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៥ ដោយមានសមាសភាពដូចតទៅ:
១-ឯកឧត្តម ............ ជាប្រធាន
២-លោក ............. ជាចៅក្រម
៣-លោក ............. ជាចៅក្រម
៤-លោក ............... ជាចៅក្រម
៥-លោក .................. ជាចៅក្រម
៦-លោក ................. ជាចៅក្រមរបាយការណ៍

**ក្រឡាបញ្ជី**
-លោក ..............

**តំណាងមហាអយ្យការ**
-លោក ................. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ៩៩(ឈ) ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៤ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៣២០ ផ្ទះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍រវាង

ដើមចោទឈ្មោះហចន (ជាម្ចាស់បណ្តឹងសាទុក្ខ)ភេទស្រី អាយុ៥៨ឆ្នាំ ជាតិខ្មែរ មុខរបរលក់អង្ករ ទីលំនៅផ្ទះលេខ១៨១ ភូមិសំរោងក្នុង ឃុំសំរោងក្នុង ស្រុកឯកភ្នំ ខេត្តបាត់ដំបង។

មានមេធាវីលោក........... ។

ចុងចម្លើយឈ្មោះប៉ិច សាម៉ុន (ជាចុងបណ្តឹងសាទុក្ខ)ភេទស្រី អាយុ៣៥ឆ្នាំជាតិខ្មែរ មុខរបរធ្វើម៉ាស៊ីនកិនស្រូវ មានទីលំនៅភូមិដំបូកខ្ពស់ ឃុំអូរដំបង២ ស្រុកសង្កែ ខេត្តបាត់ដំបង ។

កម្មវត្ថុបណ្តឹង: ប្តឹងសុំហាមឃាត់ការផ្ទេរ ឬជួល និងសុំធ្វើអាជីវកម្ម បណ្តោះអាសន្នលើរោងម៉ាស៊ីនកិនស្រូវ

បានឃើញបណ្តឹងសាទុក្ខលេខ២៨៥ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ របស់ឈ្មោះហ៊ន ចាន់នី ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៩៥"ឈ"ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ២៩៩ប្រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៤ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងរបស់ដើមចោទឈ្មោះហចន ចុះថ្ងៃទី២៥-៣-២០០៤ ថា ខ្លួនប្តឹងសុំដីកាសម្រេចកិច្ចការប្រញាប់ហាមឃាត់ការផ្ទេរ ឬជួល និងសុំសិទ្ធិធ្វើអាជីវកម្មបណ្តោះអាសន្នលើរោងម៉ាស៊ីនកិនស្រូវ ស្ថិតនៅក្រុម៨ ភូមិដំបូកខ្ពស់ ឃុំអូរដំបង២ ស្រុកសង្កែ ខេត្តបាត់ដំបង ដោយអាងហេតុថា ប៉ិច សាម៉ុន មានគំនិតមិនស្មោះត្រង់ លួចផ្ទេរ

សិទ្ធិ ឬជួយឱ្យអ្នកដទៃនៅពេល ដែលតុលាការកំពុងចាត់ការមិនទាន់ចប់អង្គសេចក្តី ។ រោងម៉ាស៊ីតនេះ ខ្លួនបានចំណាយដើមទុន រៀបចំកសាង និងគ្រប់គ្រងតាំងពីឆ្នាំ១៩៩០ មកម្ល៉េះ ។

បានឃើញដីកាសម្រេចកិច្ចការប្រញាប់លេខ០៣"ខ"ប្រ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០៤ របស់តុលាការខេត្តបាត់ដំបង ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងសុំកិច្ចការប្រញាប់គ្រប់គ្រង លើអាជីវកម្មរោងម៉ាស៊ីនកិនស្រូវ រួមជាមួយចុងចម្លើយរបស់ឈ្មោះនាង ហាចន ជាដើមចោទទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ហាមឃាត់ការចាត់ចែងគឺ : ការផ្ទេរ ជួល លក់ដូរ ឬធ្វើអំណោយនូវទ្រព្យ សម្ភារៈបម្រើ និងរោងម៉ាស៊ីនកិនស្រូវស្ថិតនៅភូមិដំបូកខ្ពស់ ឃុំអូរដំបង ស្រុកសង្កែ ខេត្តបាត់ដំបង រហូតដល់រឿងក្តីត្រូវបានសម្រេចដល់អង្គសេចក្តី ។

៣-ឱ្យឈ្មោះនាង ហាចន ជាដើមចោទមានទីលំនៅនៅភូមិសំរោងក្នុង ឃុំ សំរោងក្នុង ស្រុកឯកភ្នំ ខេត្តបាត់ដំបង និងត្រូវជាម្តាយបង្កើតរបស់ខ្មោចឈ្មោះម៉ក់ សុផាត មាន សិទ្ធិបណ្តោះអាសន្នរហូតដល់មានការសម្រេចផ្ទុយពិនេះ គឺ :

-ធ្វើអាជីវកម្ម និងគ្រប់គ្រងទ្រព្យសម្ភារៈរួមរបស់រោងម៉ាស៊ីនកិនស្រូវ ដែលមានទីតាំងនៅភូមិដំបូកខ្ពស់ ឃុំអូរដំបង ស្រុកសង្កែ ខេត្តបាត់ដំបង ។

-ចូលរួមធ្វើសកម្មភាពក្នុងកិច្ចដំណើរការងារលើផលរបរ អាជីវកម្មកិនស្រូវទាំងស្រុង ដោយគិតទាំងការចំណេញ-ខាត និងកម្រៃត្រូវទទួលបានជាប្រចាំ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តី ចំនួន ២០០០៛ ដែលដើមចោទបានបង់រួចហើយ គឺ ៖

- ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង =១៨០០៛

- រង្វាន់ក្រឡាបញ្ជីកាត់ហិបប្រាក់ =២០០៛ សរុប=២០០០៛

តាមច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ដែលប្រកាសឱ្យប្រើតាមក្រិត្យលេខ០៧ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ។

៥-សេចក្តីសម្រេចនេះ មានអនុភាពអនុវត្តភ្លាម ។

បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៤ របស់ឈ្មោះប៉ិច សាម៉ុន ប្តឹងមិនសុខចិត្តនិងដីកាសម្រេចកិច្ចការប្រញាប់លេខ០៣"ខ"ប្រ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០៤ របស់តុលាការខេត្តបាត់ដំបង ត្រង់ចំណុចដីកាសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៩៥"ឈ"ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៨-៥-២០០៤ របស់ឈ្មោះប៉ិច សាម៉ុន ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-បដិសេធចំណុចទី៣ នៃសេចក្តីសម្រេចរបស់ដីកាសម្រេចកិច្ចការប្រញាប់លេខ០៣(ខ) ចុះថ្ងៃទី០៥-៤-២០០៤ របស់តុលាការខេត្តបាត់ដំបង ចោលជាអសារបង់ ។ ចំណុច ក្រៅពីនេះរក្សាទុកជាបានការដដែល ។

៣-កាត់យកប្រាក់ប្រដាប់ក្តីដាន់សាលាឧទ្ធរណ៍១៣.០០០៛ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង២៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ៥០០០៛ និងលើអាជ្ញាធរតុលាការចំនួន៥០០០៛ ។

៤-សាលដីកានេះ ជំនុំជំរះជាសាធារណៈនៅថ្ងៃទី១៦-៧-២០០៨ ចំពោះមុខគូក្តី និងប្រកាសជាសាធារណៈនៅថ្ងៃទី២៧-៧-២០០៨ ចំពោះមុខចុងចម្លើយ កំបាំងមុខដើមចោទ តែទុកជាចំពោះមុខ ។ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ២៨៥ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ របស់ឈ្មោះហចន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៩៥"ឈ" ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

បានឃើញសរណាការពាររបស់ឈ្មោះ ហចន ។

បានឃើញសារណាតបចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៤ របស់ឈ្មោះប៉ិច សាម៉ុន ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា៖រឿងនេះជារឿងកិច្ចការប្រញាប់សូមក្រុមប្រឹក្សាជំនុំជំរះសម្រេចតាមច្បាប់។

បានស្តាប់ចម្លើយរបស់ឈ្មោះប៉ិច សាម៉ុន នាពេលសវនាការថា ខ្លួនសុំបដិសេធ និងសារណារបស់ដើមចោទ ព្រោះខ្លួនកាន់កាប់រោងមាស៊ីននេះយូរហើយ ក្រោយពីរៀបការជាមួយប្តី និងខ្លួនរួច ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក........... ជាមេធាវីការពារឱ្យដើមចោទ បានលើកឡើងថា៖ នៅឆ្នាំ១៩៩០ កូនក្តីខ្លួនបានបង្កើតរោងម៉ាស៊ីនកិនស្រូវ ។ នៅឆ្នាំ១៩៩៣ កូនក្តីខ្លួនបានពង្រីករោងម៉ាស៊ីនកិនស្រូវដោយប្រើទឹកប្រាក់របស់ខ្លួន ហើយនៅឆ្នាំ១៩៩៦ កូនប្រុសបង្កើតរបស់ខ្លួនបានរៀបការជាមួយចុងចម្លើយ ហើយឱ្យចុងចម្លើយជាអ្នកជួយមើលការខុសត្រូវក្នុងរោងម៉ាស៊ីនកិនស្រូវតែប៉ុណ្ណោះ ។ ខ្លួនសុំបដិសេធការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍ ព្រោះមានការខុសឆ្គង និងភ័ន្តច្រឡំទៅលើគោលការណ៍នៃដីកាសម្រេចកិច្ចការប្រញាប់ ។ ខ្លួនសុំដំកល់ដីកាសម្រេចកិច្ចការប្រញាប់របស់តុលាការខេត្តបាត់ដំបង ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណាការពាររបស់ដើមចោទ ចម្លើយដោះសាររបស់ចុងចម្លើយ និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីដើមចោទ .

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាបហើយ

## តុលាការកំពូល

-យល់ឃើញថាបណ្តឹងសាទុក្ខលេខ២៨៥ ចុះថ្ងៃទី២៨-០៧-២០០៤ របស់អ្នកស្រីហចន ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា តាមស្ថានភាពជាក់ស្តែង រោងម៉ាស៊ីនកិនស្រូវទំនាស់នេះ ប្តីប្រពន្ធរបស់ឈ្មោះប៉ិច សាម៉ុន ជាអ្នកកាន់កាប់ធ្វើអាជីវកម្មជារៀងរហូតមក ហើយតាមចម្លើយរបស់ឈ្មោះហចន នាពេលសវនាការសាលាឧទ្ធរណ៍ ខ្លួនបានអះអាងថា (មុនកូនខ្លួនស្លាប់) អ្នកលក់អង្ករឱ្យ និងមើលកូនឱ្យគេ ដូចនេះ រឿងកិច្ចការប្រញាប់ គឺត្រូវរក្សាស្ថានភាពដើមឱ្យនៅដដែល ។

-យល់ឃើញថា ដើមចោទបានធ្វើសារណាជូនមកតុលាការកំពូល និងបានទទួលដីកាកោះហើយ ប៉ុន្តែពុំបានចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះ កំបាំងមុខប៉ុន្តែ ចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៩៥(ឈ) ចុះថ្ងៃទី២៧-៧-២០០៤ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់.

**ហេតុដូច្នេះ**

**វិនិច្ឆ័យសចក្តីចំពោះមុខចុងចម្លើយ កំបាំងមុខដើមចោទ ប៉ុន្តែមាត់ទុកជាចំពោះមុខ**

១-ទទួលបណ្តឹងសាទុក្ខលេខ២៨៥ ចុះថ្ងៃទី២៨-៧-២០០៤ របស់អ្នកស្រីហាចន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុស នឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ៩៥(ឈ) ចុះថ្ងៃទី២៧-៧-២០០៤ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០៛ ដែលអ្នកស្រីប៊ិច សាម៉ុន បានបង់ជួស គឺ ៖

-ពន្ធចុះបញ្ជីក្តី នឹងពន្ធហ្នឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប ១៩.០០០៛ .

ហើយតម្រូវឱ្យអ្នកស្រីហាចន សងប្រាក់ចំនួន១៩.០០០៛ ទៅឱ្យអ្នកស្រីប៊ិច សាម៉ុនវិញ ។

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២ ខែសីហា ឆ្នាំ២០០៥ ។